សិក្សាចំណេះដឹងមូលដ្ឋានអំពីលុយកាក់

# បង្កើតគម្រោងថវិកា

១. គម្រោងថវិកាជាកត្តាចាំបាច់បំផុត

គម្រោងថវិកាគឺជាការចាត់ចែងខ្ទង់ចំណាយប្រាក់។ គឺមានតែការប្រើប្រាស់គម្រោងថវិកាទេទើបអាចធានាថារាល់ការចំណាយរបស់អ្នកស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងត្រឹមត្រូវហើយការចំណាយរបស់អ្នកគឺស្របទៅតាមភាគកំណត់ដែលអ្នកយល់ព្រមនៅក្នុងគម្រោង។

២. ការបង្កើតគម្រោងថវិកាត្រូវការ៣ជំហាន

- កំណត់រកឲ្យឃើញថាតើអ្នកចំណាយលុយកាក់បែបណានៅពេលឥឡូវនេះ
- វាយតម្លៃការចំណាយក្នុងពេលឥឡូវនេះនិងរៀបចំកំណត់គោលបំណងដែលពិចារណាទៅដល់ទិសដៅខាងលុយកាក់
- តាមដានរាល់ការចំណាយរបស់អ្នកដើម្បីធ្វើឲ្យប្រាកដថារាល់ការចំណាយគឺស្ថិតនៅក្នុងគន្លងមាគ៌ាដែលកំណត់ទុក

៣. ប្រើប្រាស់កម្មវិធីកុំព្យូទ័រដើម្បីជួយអ្នក

បើអ្នកប្រើកម្មវិធីកុំព្យូទ័រជួយចាត់ចែងលុយកាក់ផ្ទាល់ខ្លួនដូចជាQuicken ឬMicrosoft Money ឧបករណ៍ជំនួយដែលមានស្រាប់នៅក្នុងកម្មវិធីនោះអាចជួយអ្នកឲ្យអាចបង្កើតគម្រោងថវិកាបាន។

៤. កុំបណ្តោយឲ្យកម្មវិធីកុំព្យូទ័របង្វិលអ្នកឲ្យវង្វេងវង្វាន់

មានចំណុចមិនល្អមួយនៃការប្រើកម្មវិធីកុំព្យូទ័រដើម្បីតាមដានរាល់ការចំណាយរបស់អ្នកនោះគឺវាលើកទឹកចិត្តឲ្យអ្នកផ្តោតអារម្មណ៍ទៅលើចំណុចលំអិតតូចៗ។ នៅពេលណាដែលអ្នករកឃើញថាខ្ទង់ចំណាយណាមួយដែលអាចឬគួរតែកាត់បន្ថយ(ឬបង្កើន) សូមផ្តោតចំណាប់អារម្មណ៍លើខ្ទង់ចំណាយនោះនិងកុំស្វះខ្វល់ពេកជាមួយនឹងការចំណាយផ្សេងទៀត។

៥. តាមដានរាល់ការចំណាយដែលប្រើលុយសុទ្ធ

បើសិនការដកលុយចេញពីម៉ាស៊ីនដកលុយដោយស្វ័យប្រវត្តិ(ATM)ធ្វើឲ្យអ្នកចាយវាយខ្ជះខ្ជាយលុយពីហោប៉ៅអ្នកដោយគ្មានការបកស្រាយច្បាស់លាស់ទេ គឺល្មមដល់ពេលកត់ត្រារាល់ការចំណាយទាំងនោះហើយ។ ជាទូទៅបើអ្នកយល់ឃើញថាអ្នកត្រឡប់ទៅម៉ាស៊ីនអេធីអឹមច្រើនដងក្នុងមួយសប្តាហ៍ អ្នកត្រូវតែពិនិត្យមើលថាតើលុយទាំងនោះវាហៀរចេញទៅទិសណា។

៦. ការចំណាយហួសកម្រិតគឺជាការគ្រោះថ្នាក់ខ្លាំងណាស់

ប៉ុន្តែបើអ្នកពិតជាមនុស្សនៅក្នុងក្រុមនេះមែន គឺមានមនុស្សច្រើនណាស់ដែលមានលក្ខណៈដូចអ្នក។ តួលេខខាងរដ្ឋាភិបាល បង្ហាញថាគ្រួសារជាច្រើនដែលមានចំណូល៥ម៉ឺនដុល្លាឬតិចជាងនោះក្នុងមួយឆ្នាំចំណាយខ្ជះខ្ជាយចោលច្រើនលើសពីលុយដែលគេយកចូលផ្ទះ។ ការនេះមិនបានធ្វើឲ្យអ្នកក្លាយទៅជាបេក្ខជនសម្រាប់ការខ្ស័យធនដោយស្វ័យប្រវត្តិទេ ក៏ប៉ុន្តែវាគឺពិតជាសញ្ញាមួយដែលអ្នកចាំបាច់ត្រូវម៉ឹងម៉ាត់ចំពោះខ្លួនឯងដើម្បីជំរុះចោលការចំណាយទាំងនោះ។

៧. ប្រុងប្រយ័ត្នចំពោះគ្រឿងលំអប្រណិតឆើតឆាយដែលអ្នកគិតថាវាចាំបាច់

បើប្រាក់ចំណូលរបស់អ្នកមិនអាចបំពេញបានតាមតម្លៃនៃរបស់របរទាំងនោះទេ ដូច្នេះការចំណាយរបស់អ្នកប្រហែលជាធ្លាក់ទៅលើគ្រឿងរបស់លំអឆើតឆាយហើយអ្នកប្រហែលបានយល់ដោយច្រឡំថាគ្រឿងរបស់ទាំងនោះជារឿងចាំបាច់។

៨. ចេញថ្លៃឲ្យខ្លួនអ្នក១ភាគ១០នៃប្រាក់ចំណូល

ត្រូវមានគម្រោងថាមិនត្រូវចំណាយលើសពី៩០ភាគរយនៃប្រាក់ចំណូលរបស់អ្នកទេ។ វិធីនេះអ្នកនឹងមានប្រាក់១០ភាគរយក្នុងបញ្ជីសន្សំសម្រាប់គោលបំណងធំៗ។

៩. កុំរំពឹងលើប្រាក់ដែលមិនដឹងប្រាកដថានឹងបានឬអត់

ពេលធ្វើគម្រោងវាយតម្លៃបរិមាណទឹកលុយដែលអ្នកអាចរស់បាន សូមកុំបូកបញ្ចូលលុយដែលអ្នកមិនអាចប្រាកដថានឹងទទួលបានដូចជាប្រាក់បន្ថែមចុងឆ្នាំ លុយបានពីការសងមកវិញរបស់ខាងពន្ធដារ ឬលុយបានពីផលចំណេញនៃការបណ្តាក់ទុន។

១០. ប្រយ័ត្នចំពោះការចំណាយដែលចេះតែមកអន្ទងអ្នក

នៅពេលដែលប្រាក់ចំណូលប្រចាំឆ្នាំរបស់អ្នកកាន់តែកើនឡើង ឋានៈរបស់អ្នកក៏ឡើង បណ្តាក់ទុនក៏បានផលកម្រៃច្រើន សូមកុំបណ្តោយឲ្យគំនិតប្រុងចំណាយលើគ្រឿងលំអមកលងឬអន្ទងចិត្តអ្នកឲ្យសោះលុះត្រាតែអ្នកប្រាកដខ្លួនឯងថាអ្នកនៅឆ្ងាយហួសពីអតិផរណា(inflation)។ វាជាការប្រសើរដែលអ្នកយកលុយលើសនោះទុកចូលក្នុងគណនីសន្សំរបស់អ្នក។